# ការគោរពព្រះពុទ្ធបាទ

ពុទ្ធសាសនិកជឿថា ព្រះពុទ្ធបាទ គឺបានបន្សល់ទុកដោយព្រះពុទ្ធសក្យមុនី បើទោះបីជាមានព្រះពុទ្ធជាច្រើនអង្គបានត្រាស់ និងចូលបរិនិព្វានក្តី។[១] ជាទូទៅគេឃើញមានចម្លាក់ និងគំនូរដែលទាក់ទងនឹងជើង ដូចជាព្រះពុទ្ធទ្រង់ដើរ៧ជំហ៊ាននៅលើផ្កាឈូកបន្ទាប់ពីព្រះអង្គបានប្រសូត ព្រះអង្គដើរនៅលើទឹកទន្លេនរញ្ជនា ការចេញសាងព្រះផ្នួស និងការយាងចុះពីស្ថានត្រៃត្រឹង្ស។ នៅក្នុងសិល្បៈឥណ្ឌាជំនាន់ដើម ព្រះពុទ្ធមិនបានបង្ហាញក្នុងទម្រង់រូបរាងជាមនុស្សពេញលេញដូចក្នុងពេលបច្ចុប្បន្ននេះទេ។

វត្តមានរបស់ទ្រង់បង្ហាញក្នុងទម្រង់ជារូបតំណាង ដូចជាព្រះបាទ ដើមពោធិ ធម្មចក្រ បល្ល័ង្ក និងចេតិយ។[២] រូបតំណាងទាំងនេះបានបង្ហាញក្នុងសិល្បៈឥណ្ឌាក្នុងពេលជំណាលគ្នា។[៣]

ពុទ្ធបាទដំបូងៗ បានលេចឡើងលើចម្លាក់ចេតិយ នៅសាន់ឈី បារហ៊ូត និងនៅអមរាវទី ឯស្រុកឥណ្ឌា។ តើហេតុអ្វីបានជាពុទ្ធសាសនិកនៅតែបន្តគោរពព្រះពុទ្ធបាទយ៉ាងខ្ជាប់ខ្ជួន បើប្រៀបធៀបទៅនឹងរូបតំណាងដទៃទៀត?

តាមប្រពៃណី ការគោរពបូជាដានជើង គឺមានទាំងក្នុងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ដូច្នេះត្រឹមតែទម្រង់ដានជើងទទេ គឺមិនអាចសន្និដ្ឋានថា ដានជើងនោះជាដានជើងរបស់ព្រះឥសូរ (ទេពក្នុងព្រហ្មញ្ញសាសនា) ឬដានជើងរបស់ព្រះពុទ្ធឡើយ។ ក៏ប៉ុន្តែបរិបទនៅជុំវិញ និងចំណេះដឹងរបស់សាសនិកអាចឱ្យគេកំណត់អត្តសញ្ញាណរបស់ព្រះបាទនោះបាន។ ជាទូទៅ នៅក្នុងសិល្បៈព្រះពុទ្ធសាសនាសម័យដើម គេឆ្លាក់ព្រះពុទ្ធបាទដោយមានកងចក្រ ប៉ុន្តែនៅក្នុងសម័យក្រោយមកទៀតបែរជានិយមបង្ហាញព្រះពុទ្ធបាទដែលមានសញ្ញាមង្គលទាំង១០៨ជំនួសវិញ (រូបលេខ១-២)។[៤] រូបតំណាងរបស់ព្រះពុទ្ធបានបង្ហាញក្នុងចម្លាក់ដាច់ដោយឡែកពីគ្នា ប៉ុន្តែមានករណីខ្លះក៏បានបង្ហាញរួមជាមួយគ្នាក៏មាន។ ការបង្ហាញរូបតំណាងព្រះពុទ្ធនៅរួមគ្នាបង្ហាញឱ្យឃើញអំពីភាពសំខាន់ផ្សេងគ្នាយ៉ាងច្បាស់លាស់ គឺព្រះពុទ្ធបាទទទួលបានការគោរពយ៉ាងខ្លាំងបំផុត។

---

[១] Huntington, L. Susan 1990:3

[២] Huntington, L. Susan 1990:2

[៣] Huntington, L. Susan 1990:401-406

[៤] Su Latt Win 2017:4

អត្ថបទដោយ៖ មាស សុភាព

ក្នុងរូបភាពនេះបង្ហាញថា មនុស្សជាច្រើនបានគោរពរូបតំណាងផ្សេងៗរបស់ព្រះពុទ្ធ ប៉ុន្តែមានតែមនុស្សដែលគោរពព្រះពុទ្ធបាទប៉ុណ្ណោះ ដែលមានកាយវិការអោនលំទោនយ៉ាងខ្លាំង (រូបលេខ៣)។

បើពិនិត្យទៅលើរូបតំណាងទាំង៥របស់ព្រះពុទ្ធ ពុទ្ធបាទ ដើមពោធិ បល្ល័ង្ក ធម្មចក្រ និងចេតិយ ឃើញថាមានរបស់បួនយ៉ាងដែលតំណាងឱ្យទីកន្លែង និងព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងដំណើរជីវិតរបស់ព្រះអង្គ។ ដើមពោធិ តំណាងឱព្រះអង្គក្នុងពេលត្រាស់ដឹង។ បល្ល័ង្ក តំណាងឱ្យព្រះអង្គក្នុងពេលសំដែងធម្មទេសនានៅសារនាថ។ ធម្មចក្រ តំណាងឱ្យព្រះធម៌ និងវាលវដ្តសង្សា រីឯចេតិយតំណាងឱ្យព្រះអង្គពេលដែលយាងចូលបរិនិព្វាន។ ដោយឡែក ពុទ្ធបាទ ឬស្នាមព្រះពុទ្ធបាទ ជាផ្នែកតែមួយគត់ដែលជាប់ទាក់ទងនឹងព្រះកាយរបស់ព្រះអង្គ។ ជាធម្មតាជានដើងមនុស្សម្នាក់ បញ្ជាក់អត្តសញ្ញាណរបស់មនុស្សនោះ ឬជាទូទៅសំដៅទៅលើមនុស្សនោះតែម្តង ដូច្នេះពុទ្ធបាទ គឺជារូបរបស់ព្រះពុទ្ធផ្ទាល់។

ក្នុងទស្សនៈព្រះពុទ្ធសាសនា ព្រះពុទ្ធមានព្រះកាយពីរ រូបកាយ និងធម្មកាយ។ រូបកាយរបស់ព្រះពុទ្ធបានចូលបរិនិព្វាន និងខន្ធទាំងអស់បានបែកខ្ចេចទៅតាមធម្មជាតិ ក៏ប៉ុន្តែធម្មកាយរបស់ព្រះអង្គគង់នៅជាធរមាន។ តាមរយៈព្រះធម្មទាំងឡាយដែលសាសនិកកំពុងប្រតិបត្តិ នាំឱ្យគេឃើញថាព្រះកាយរបស់ព្រះអង្គនៅមានវត្តមាននៅឡើយ។ ព្រះអង្គ មានរូបដែលមិនមែនជារូប គឺមានន័យថាទទេ[៥] ដែលជាទូទៅពុទ្ធសាសនិកធ្លាប់ស្គាល់ថាអនត្តា គឺមិនមែនជារបស់ចិត្ត របស់ខ្លួន ឬដែលគ្មានខ្លឹមសារ។[៦]

សរុបមកព្រះពុទ្ធបាទ គឺជាព្រះកាយរបស់ព្រះពុទ្ធក្នុងទម្រង់ជាមនុស្ស មុនពេលមានរូបរាងពេញលេញ គឺជាសរីរៈ ឬផ្នែកនៃរូបកាយ ឬជារូបកាយទាំងមូលរបស់ព្រះពុទ្ធតែម្តង។ វាជាទម្រង់ដែលមានសារសំខាន់បំផុតដែលពន្យល់ឱ្យឃើញអំពីការយល់ដឹងរបស់សិល្បករ និងពុទ្ធសាសនិកអំពីវត្តមាន និងអវត្តមានរបស់ព្រះពុទ្ធ និងព្រះធម៌។ អាស្រ័យដូចនេះហើយទើបពុទ្ធសាសនិកនៅតែបន្តកសាងព្រះពុទ្ធបាទដាក់តំកល់គោរពបូជា រួមជាមួយនឹងបដិមាព្រះពុទ្ធដែលមានទម្រង់ជាមនុស្សពេញលេញ។

[៥] Seckel, Dietrich 2004:11

[៦] Caroli, D.Robert 2008:30

អត្ថបទដោយ៖ មាស សុភាព



រូបលេខ១-២៖ ព្រះពុទ្ធបាទខាងស្តាំ និងខាងឆ្វេង មកពីថែវព្រះពាន់ ប្រាសាទអង្គរវត្ត

អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ៖ ការលំទោនគោរពព្រះពុទ្ធបាទ និងការគោរពរូបតំណាងផ្សេងៗរបស់ព្រះពុទ្ធ
( ចម្លាក់ក្រឡោតទាបមកពីចេតីយនៅសាន់ឈី)

## ឯកសារពិគ្រោះ

Caroli, D. Robert.
2008. 'From living rock: Understanding figural Representation in early Southeast Asia,' *University of Hawaii Press.* p. 21-45

Huntington, L. Susan.
1990. 'Early Buddhist Art and the Theory of Aniconism.' *Art Journal.* Vol.49, No.4. p. 401-408.

Huntington, L. Susan.
2015. 'Shifting the paradigm: The aniconic theory and its terminology.' *South Asian Studies,* Vol.31, No.2 (2015): 163-186.

Seckel, Dietrich.
2004. Before and Beyond the Image. Switzerland: Artibus Asiae.

Su Latt Win.
2017. 'The significance of the Buddha Footprint in the Bagan Metropolis' *SOAS.* p.1-15.

អត្ថបទដោយ៖ មាស សុភាព